OFFICE OF THE COMPLIANCE ADVISOR/OMBUDSMAN
2121 PENNSYLVANIA AVENUE, NW • WASHINGTON, DC 20433, USA
TELEPHONE + 1 202 458 1973 • FACSIMILE + 1 202 522 7400
CAO@worldbankgroup.org

# សេចក្តីប្រកាសព័ត៌មាន

## ដំណើរការដោះស្រាយវិវាទរវាងសហគមន៍មូលដ្ឋាន និងក្រុមហ៊ុន ទាក់ទងនឹងផលប៉ះពាល់នៃការវិនិយោគចំការដំណាំក្នុងខេត្តរតនគិរី

ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩៖ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ការិយាល័យ ស៊ីអេអូ) ក្នុងនាមជាយន្តការគណនេយ្យភាពឯករាជ្យមួយនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលជាសាខាវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក កំពុងចូលរួមនៅក្នុងព្រឹត្តិការណ៍មួយដែលរៀបចំឡើងដោយរដ្ឋាភិបាលខេត្តរតនគិរី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញអំពីសមិទ្ធផល និងមេរៀនបទពិសោធ៍ទាក់ទងនឹងដំណើរការសន្ទនាមួយ ដែលផ្តួចផ្តើមដោយការិយាល័យ ស៊ីអេអូ។

ចាប់តាំងពីខែមីនា ឆ្នាំ២០១៤ រហូតដល់ខែមករា ឆ្នាំ២០១៩ ការិយាល័យស៊ីអេអូ បានរៀបចំឱ្យមានដំណើរការសន្ទនាមួយ រវាងក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ (HAGL) ដែលជាប្រតិបត្តិករដំណាំចំការកៅស៊ូមួយក្នុងខេត្តរតនគិរី នៃព្រះរាជាណាចក្រកម្ពុជា និង ភូមិក្នុងមូលដ្ឋានដែលរងផលប៉ះពាល់ ដើម្បីដោះស្រាយបញ្ហាកង្វល់ពាក់ព័ន្ធនឹងផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គមដែលបណ្តាលពីដំណាំចំការទាំងនេះ។

ពាក្យបណ្តឹងដែលជម្រុញឱ្យមានការចូលរួមពីការិយាល័យ ស៊ីអេអូ ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ត្រូវបានធ្វើឡើងដោយសហគមន៍ចំនួន១៧ ក្នុងខេត្តរតនគិរី ទៅលើក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ ដែលធ្វើប្រតិបត្តិការដំណាំកៅស៊ូនៅក្នុងតំបន់នេះ។ ដើមបណ្តឹង ដែលបានស្នើសុំឱ្យរក្សាការសម្ងាត់ បានលើកឡើងនូវបញ្ហាកង្វល់មួយចំនួនទាក់ទងនឹងការបាត់បង់ដីធ្លី និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ។

កន្លងមក មានកិច្ចព្រមព្រៀងគួរឱ្យកត់សម្គាល់មួយចំនួនដែលបានឯកភាពគ្នាតាមរយៈកិច្ចសន្ទនា ទាក់ទងនឹងការប្រគល់ដីត្រឡប់មកវិញ ការស្តារផ្លូវទឹក និងការជួសជុលផ្លូវ ព្រមទាំងបញ្ហាដទៃទៀត។ ការអនុវត្តកិច្ចព្រមព្រៀងទាំងនេះកំពុងបន្ត។ គូភាគីបានសុំការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតឱ្យមានក្រុមការងារចម្រុះថ្នាក់ខេត្តមួយ ដើម្បីធ្វើការប្រាស្រ័យទាក់ទងនៅក្នុងដំណើរការសន្ទនា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។

យោងតាមឯកសាររបស់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានឱ្យដឹងថា គិតត្រឹមពេលដែលពាក្យបណ្តឹងត្រូវបានធ្វើឡើង ក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ គឺជាក្រុមហ៊ុនវិនិយោគមួយរបស់ក្រុមហ៊ុនវិនិយោគសហគ្រាសវៀតណាមចំកាត់ (VEIL)។ សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានវិនិយោគថវិកាមូលនិធិចំនួន ១២ លានដុល្លារសហរដ្ឋអាមេរិក ដែលថវិកានេះគ្រប់គ្រងដោយក្រុមហ៊ុនដ្រេហ្គិនខាភីថលម៉ាណេជមិន (Dragon Capital Management Ltd) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនដ្រេហ្គិនខាភីថលគ្រូប (Dragon Capital Group)។

ព័ត៌មានលម្អិតអំពីករណីនេះអាចរកមើលបាននៅឯ: www.cao-ombudsman.org

**បុគ្គលទំនាក់ទំនងនៅឯការិយាល័យប្រចាំទីក្រុងវ៉ាស៊ីនតោន ឌីស៊ី៖**

អេមីលី ហារហ្គិន (Emily Horgan)
ទូរស័ព្ទ៖ +1.202.473.8353
អ៊ីមែល៖ ehorgan@worldbankgroup.org

---

**អំពីការិយាល័យ ស៊ីអេអូ៖**

*ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ការិយាល័យ ស៊ីអេអូ) គឺជាយន្តការឧបាស្រ័យ និងគណនេយ្យភាព របស់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសាខាផ្តល់ឥណទាន និងធានារ៉ាប់រងជូនវិស័យឯកជន របស់ក្រុមធនាគារពិភពលោក។ បង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ការិយាល័យ ស៊ីអេអូ រាយការណ៍ដោយផ្ទាល់ជូនប្រធានក្រុមធនាគារពិភពលោក។ ការិយាល័យ ស៊ីអេអូ មានអាណត្តិការងារដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ក្នុងលក្ខណៈមួយដែលយុត្តិធម៌ ឥតលម្អៀង និង ប្រកបដោយភាពស្ថាបនា ក្នុងគោលដៅរួមសំដៅលើកកម្ពស់លទ្ធផលការងារផ្នែកសង្គម និងបរិស្ថាននៅមូលដ្ឋាន និង ជម្រុញឱ្យ IFC និង MIGA មានគណនេយ្យភាពកាន់តែខ្លាំងឡើងចំពោះសាធារណជន។*